ធ្វើឱ្យរហាលនៅពេលដែលគំរបព្រៃចាប់ផ្តើមគ្របដីជិត ហើយដើមឈើមានការប្រកួតប្រជែងរវាងគ្នាដោយៈ

- កាប់ដកហូតនូវដើមឈើដែលគ្មានគុណភាពល្អ ដើមឈើវៀចកោង មានមែកច្រើន ឬគ្មានតំលៃ
- កាប់ដកហូតនូវដើមឈើដែលទាប តូច និងមិនសូវត្រង់
- កាប់ដកហូតនូវដើមឈើផ្តល់ម្លប់ខ្លះដើម្បីបង្កើនពន្លឺថ្ងៃ។

***សូមប្រើប្រាស់ទំព័របន្ថែម និង ឧបសម្ព័ន្ធនានាដូចខាងក្រោមៈ***

ឧបសម្ព័ន្ធទី ១: ការរជ្រើសរើសប្រភេទឈើ

ឧបសម្ព័ន្ធទី ២: លទ្ធកម្មគ្រាប់ពូជ

ឧបសម្ព័ន្ធទី ៣: ការងារនៅថ្នាលបណ្តុះកូនឈើ

ឧបសម្ព័ន្ធទី ៥: ការថែរក្សាចំការឈើដាំ

ឧបសម្ព័ន្ធទី ៦: គោលការណ៍ណែនាំសំរាប់ការធ្វើសេចក្តីសំរេចចិត្តក្នុងការស្តារដីព្រៃឡើងវិញ

ឧបសម្ព័ន្ធទី ៧: ជំរើសដោយសាមញ្ញសំរាប់ការកំណត់ដង់ស៊ីតេនិងប្រភេទឈើដែលដុះដោយធម្មជាតិ

ឧបសម្ព័ន្ធទី ១០: ប្រភេទឈើមួយចំនួនដែលផ្តល់ផលិតផលបន្ថែមក្រៅពីឈើ

ទំព័របន្ថែមទី ១: ការធ្វើផែនការគ្រប់គ្រងចំការឈើដាំ

## ៤. *វិធីសាស្ត្រ* Framework Species

វិធីសាស្ត្រ "Framework Species" ត្រូវបានបង្កើតឡើងដើម្បីស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់ព្រៃរេចរិល ក្នុងគោលបំណងអភិរក្សនូវជីវចំរុះ និង ការការពារបរិស្ថាន។ នៅក្នុងទីតាំងដែលព្រៃឈើរេចរិលខ្លាំងហើយព្រៃឈើមិនអាចស្តារឡើងវិញតាមរយៈការដាំដើមឈើដោយ ធម្មតា នោះគេត្រូវប្រើវិធីសាស្ត្រ "Framework Species"។ វិធីនេះពឹងផ្អែកទាំងស្រុងលើវត្តមាននៃដំណុះព្រៃធម្មជាតិ (ដែលមិនទាន់ប៉ះពាល់) នៅមានសេសសល់នៅក្បែរទីតាំងដែលត្រូវស្តារដីព្រៃឈើឡើងវិញដើម្បីជាប្រភពផ្តល់គ្រាប់ពូជ។ លើសពីនោះទៀតត្រូវមានវត្តមាននៃពពួកសត្វព្រៃច្រើនគួរសមនៅក្នុងតំបន់ព្រៃក្បែរៗនោះ ដើម្បីជួយពង្រាយគ្រាប់ពូជពីតំបន់ព្រៃធម្មជាតិទៅក្នុងតំបន់ដែលត្រូវស្តារដីព្រៃឈើឡើងវិញ។ ការងារនេះអាចសំរេចជោគជ័យដោយការដាំចំរុះ នូវប្រភេទឈើដែលធ្លាប់មានដុះនៅនឹងទីកន្លែងចំនួន ២០-៣០ ប្រភេទ ដោយរួមមានទាំងប្រភេទដែលមានផ្លែផ្កាទាក់ទាញសត្វព្រៃផងដែរ។

ការដាំដើមឈើនឹងជួយស្តារឡើងវិញនូវរចនាសម្ព័ន្ធ និង មុខងារនៃប្រព័ន្ធអេកូឡូស៊ី នៅពេលដែលសត្វព្រៃដែលជាភ្នាក់ងារពង្រាយគ្រាប់ពូជនឹងជួយបង្កើតជីវចំរុះ និង សារព័ន្ធរុក្ខជាតនៃព្រៃឈើឱ្យដូចដើមឡើងវិញ។ ប្រសិនបើអវត្តមានកត្តាណាមួយក្នុងចំណោមកត្តាទាំងពីរនេះនៅជុំវិញតំបន់ដែលត្រូវស្តារដីព្រៃឈើឡើងវិញ នោះវិធីសាស្ត្រ "Framework Species មិនអាចអនុវត្តបានទេ។ ក្នុងករណីដែលវិធីសាស្ត្រ "Framework Species មិនអាចមាន

លទ្ធភាពទាក់ទាញឱ្យមានដំណុះព្រៃដោយធម្មជាតិ នោះការដាំបញ្ចូលបន្ថែមនូវប្រភេទឈើ មួយចំនួនទៀតក្នុងរយៈពេលបន្ទមកទៀតគឺជាការចាំបាច់។ ប្រភេទឈើដែលអាចប្រើប្រាស់ក្នុងបច្ចេកទេស "Framework Species គឺបណ្តាប្រភេទឈើទាំងឡាយណាដែលមានអត្រារស់ និង អត្រាដុះលូតលាស់ខ្ពស់ជាងគេនៅពេលដែលយកមកដាំនៅក្នុងតំបន់ដីព្រៃរេចរិល។ វិធីសាស្ត្រ "Framework Species ងាយនឹងបង្កើតគំរបព្រៃក្រាស់ឡើងវិញដែលអាចកំចាត់ពពួកស្មៅចង្រៃ ទាក់ទាញពពួកសត្វព្រៃដែលជាភ្នាក់ងារពង្រាយគ្រាប់ពូជ ជាពិសេសសត្វស្លាប និង ប្រចៀវ។ (សំរាប់ការអនុវត្តជាក់ស្តែងសូមមើល រូបភាពនៅទំព័របន្ទាប់)។

***សូមប្រើប្រាស់ទំព័របន្ថែម និង ឧបសម្ព័ន្ធនានាដូចខាងក្រោមៈ***

ឧបសម្ព័ន្ធទី ១: ការជ្រើសរើសប្រភេទឈើ

ឧបសម្ព័ន្ធទី ២: លទ្ធកម្មគ្រាប់ពូជ

ឧបសម្ព័ន្ធទី ៣: ការងារនៅថ្នាលបណ្តុះកូនឈើ

ឧបសម្ព័ន្ធទី ៤: ការងារនៅចំការដាំឈើ

ឧបសម្ព័ន្ធទី ៥: ការថែរក្សាចំការឈើដាំ

ទំព័របន្ថែមទី១: ការគណនាតំរូវការគ្រាប់ពូជឈើ

# វិធីសាស្ត្រ Framework Species សំរាប់ការស្តារដីព្រៃរេចរិលឡើងវិញ




រៀបចំទីតាំងដោយកាប់សំអាតស្មៅ តែត្រូវរក្សាទុកនូវដំណុះកូនឈើដែលមានស្រាប់នៅនឹងទីកន្លែង




ដាំឈើក្នុងស្រុកចំរុះប្រភេទ ពី ២០-៣០ ប្រភេទ ដោយរួមមានទាំង ប្រភេទដែលងាយបោះទីតាំងមុន (នៅក្នុងរូបបង្ហាញដោយពិតបៃតង) និង ប្រភេទឈើដើមធំៗ (ក្នុងរូបបង្ហាញដោយពិតក្រហម) ក្នុង គំលាត ១,៦ម-១,៨ម ។




ប្រភេទឈើដែលបោះទីតាំងមុន (ពតិខៀវ) ដុះលូតលាស់លឿនណាស់ បង្កើតបានជាគំរបព្រៃស្រទាប់លើហើយជួយ ក្នុងការទាក់ទាញពពួកសត្វដែលពង្រាយគ្រាប់ពូជ។ ប្រភេទឈើដែលដុះលូតលាស់យឺត បង្កើតបានជាគំរបព្រៃស្រទាប់បន្ទាប់ (ពតិក្រហម)។ គ្រាប់ពូជដែលនាំមកដោយសត្វព្រៃ ដុះលូតលាស់ បង្កើតបានជាស្រទាប់ព្រៃដែលបង្កើតដោយធម្មជាតិ (ពតិបៃតង)។




បន្ទាប់ពីរយៈពេល១០-២០ឆ្នាំ ប្រភេទដែលបោះទីតាំងមុនចាប់ផ្តើមងាប់ជាបណ្តើរៗ ដែលផ្តល់នូវសារធាតុចិញ្ចឹមដល់ពពួកសត្វបាណកជាតិ។ ប្រភេទឈើនៃសារព័ន្ធព្រៃពេញរូបរាងដែលដុះលូតលាស់យឺត បង្កើតបានជាគំរបព្រៃស្រទាប់ខ្ពស់ (ពតិក្រហម)។ ចំណែកដើមឈើដែលដុះដោយធម្មជាតិ បង្កើតបានជាស្រទាប់ក្រោម(ពតិបៃតង)។ ព្រៃប្រភេទនេះ បាន និង កំពុងវិវឌ្ឍន៍ទៅរកការកកើតជីវចំរុះដូចសភាពដើមវិញ។

ប្រភព: *FOREST RESTORATION RESEARCH UNIT, 2000.*